ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៧១៦ សហវ.ហក

# ប្រកាសអន្តរក្រសួង

## ស្តីពី

## គោលការណ៍សម្រាប់ប្រមូលផ្តុំហ្វឹកហាត់ ក្រុមជម្រើសជាតិ និងការប្រកួតលក្ខណៈអន្តរជាតិផ្លូវការប្រចាំឆ្នាំ

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** **រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹតលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពី ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការអប់រំ

-បានឃើញអនុក្រឹត្យលេខ០៤ អនក្រ.បក. ចុះថ្ងៃទី២០ ខែ មករា ឆ្នាំ ២០០០ ស្តីពី ការរៀបចំ និងប្រព្រឹត្តិទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹតលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៤ ស្តីពី ការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹតលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី១១ ខែ ឧសភា ឆ្នាំ ២០១៥ ស្តីពី ការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញប្រកាសអន្តរក្រសួងលេខ ១៣២ សហវ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីគោលការណ៍សម្រាប់ហ្វឹកហាត់ និង ការប្រកួតកីឡាជាផ្លូវការគ្រប់ប្រភេទប្រចាំឆ្នាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំយុវជន និងកីឡា

-បានឃើញប្រកាសអន្តរក្រសួងលេខ ៣៨១ សហវ.ហក ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ ២០០៩ ស្តីពី គោលការណ៍ចំណាយសម្រាប់ការប្រមូលផ្តុំហ្វឹកហាត់ក្រុមជម្រើសជាតិ និងការប្រកួតលក្ខណៈអន្តរជាតិផ្លូវការប្រចាំឆ្នាំ

-បានឃើញលិខិតលេខ ៩៨៣៩ សហវ.ហក ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ ២០១៤ ស្តីពីការបន្ថែមប្រាក់ របបអាហារបំប៉នកីឡាជម្រើសជាតិ និងប្រាក់អាហារូបត្ថម្ភហូបចុក សម្រាប់ប្រតិភូ និងកីឡាករ ចូលរួមគ្រប់ប្រភេទក្នុងប្រទេស ចាប់ពីឆ្នាំ ២០១៥ តទៅ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-អនុឡោមតាមការចាំបាច់ និង ជាក់ស្តែងចំពោះមុខ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

# សម្រេច

## ជំពូកទី ១

## បទបញ្ញត្តិទូទៅ

**ប្រការ ១.**

ប្រកាសនេះមានគោលដៅកំណត់ប្រាក់រង្វាន់ ជ័យលាភី ដល់កីឡាករ កីឡាការិនីជម្រើសជាតិ គ្រូបង្វឹក គ្រូជំនួយ និងអនុរក្ស ដែលត្រូវបានជ្រើសរើស ឲ្យធ្វើការរៀបចំហ្វឹកហាត់ និងចូលរួមប្រកួតជាលក្ខណៈអន្តរជាតិ ។

**ប្រការ ២.**

កីឡាករ កីឡាការិនីជម្រើសជាតិ គឺជាកីឡាករ កីឡាការិនីដែលមានកម្រិតបច្ចេកទេសខ្ពស់ មានវិន័យ សីលធម៌ល្អ និងមានឆន្ទៈមោះមុត ហើយត្រូវបានជ្រើសរើសដោយគណៈកម្មការបច្ចេកទេស ក្រសួងអប់រំ យុវជន និងកីឡា ដែលមានសមាសភាពមកពីមជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា និងសហព័ន្ធកីឡាជាតិ ក្រោយពីបានឆ្លងកាត់ការប្រកួតជ្រើសរើសជើងឯកប្រចាំឆ្នាំរួចមក ។

**ប្រការ ៣.**

ចំនួនប្រភេទកីឡា ចំនួនវិញ្ញាសា ចំនួនកីឡាករ កីឡាការិនី ចំនួនអនុរក្ស ចំនួនគ្រូបង្វឹកក្នុងការប្រមូលផ្តុំហ្វឹកហាត់នឹងត្រូវកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា ។

**ប្រការ ៤.**

ការប្រមូលផ្តុំហ្វឹកហាត់ក្រុមកីឡាជម្រើសជាតិ ត្រូវផ្អែកលើគោលការណ៍បច្ចេកទេស ដែលបានកំណត់ដោយមជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា ។

## ជំពូកទី ២

## អំពីការឧបត្ថម្ភ ការប្រមូលផ្តុំ និងការហ្វឹកហាត់

**ប្រការ ៥.**

ដើម្បីធានាគុណភាព នៃការហ្វឹកហាត់ក្នុងរយៈពេលប្រមូលផ្តុំ គ្រូបង្វឹក អនុរក្ស និងកីឡាករ កីឡាការិនីជម្រើសជាតិម្នាក់ៗ ត្រូវទទួលបានប្រាក់ឧបត្ថម្ភដូចខាងក្រោម ៖

**ក-ការហ្វឹកហាត់ក្នុងប្រទេស ៖**

ក.១-ប្រាក់ឧត្ថម្ភ ៖

| | | | | |
|---|---|---|---|---|
| ១-គ្រូបង្វឹក | ០១នាក់ | ផ្តល់ជូនក្នុងមួយខែ | ចំនួន | ៦០០.០០០ រៀល |
| ២-អនុរក្ស | ០១នាក់ | ផ្តល់ជូនក្នុងមួយខែ | ចំនួន | ៣០០.០០០ រៀល |
| ៣-កីឡាករ | ០១នាក់ | ផ្តល់ជូនក្នុងមួយខែ | ចំនួន | ៥០០.០០០ រៀល |

ក.២-អាហារបំប៉ន ៖

គ្រូបង្វឹក អនុរក្ស និងកីឡាករ កីឡាការិនីជម្រើសជាតិ ត្រូវទទួលបានរបបអាហារបំប៉នស្មើនឹងទឹកប្រាក់ចំនួន ៤៤.០០០ រៀល ក្នុង០១នាក់ ក្នុង០១ថ្ងៃ ។

**ខ-ការចេញទៅហ្វឹកហាត់ក្រៅប្រទេស ៖**

អនុរក្ស គ្រូបង្វឹក កីឡាករ កីឡាការិនីជម្រើសជាតិ ដែលបានជ្រើសរើសឲ្យទៅធ្វើការហ្វឹកហាត់នៅក្រៅប្រទេស ត្រូវទទួលបានប្រាក់ឧបត្ថម្ភដូចខាងក្រោម ៖

-ចាប់ពី ១ខែ ឡើងទៅ ផ្តល់ជូនចំនួន ១.៨០០.០០០ រៀល ក្នុង ១ខែ ក្នុង ១នាក់

-តិចជាង ១ខែ ផ្តល់ជូនតាមរបបបេសកកម្មដែលរដ្ឋបានកំណត់

-អនុរក្ស គ្រូបង្វឹក និងកីឡាករ កីឡាការិនីជម្រើសជាតិ ដែលទទួលបានប្រាក់ឧបត្ថម្ភខាងលើមិនត្រូវបានទទួលប្រាក់ឧបត្ថម្ភផ្សេងទៀតទេ ។

## ជំពូកទី ៣
## អំពីប្រាក់រង្វាន់ ជ័យលាភី
## សម្រាប់កីឡាករ កីឡាការិនី គ្រូបង្វឹក និងគ្រូជំនួយ

**ប្រការ ៦.-**

ប្រាក់រង្វាន់លើកទឹកចិត្តដល់គ្រូបង្វឹក គ្រូជំនួយ កីឡាករ កីឡាការិនីដែលទទួលជ័យលាភីក្នុងការប្រកួតជាលក្ខណៈអន្តរជាតិក្នុងប្រទេស ក្រៅប្រទេស លក្ខណៈហ្គេម (Games) និងជើងឯក (Championship) គ្រប់ប្រភេទកីឡាមានដូចខាងក្រោម ៖

**ក-ប្រាក់រង្វាន់លើកទឹកចិត្ត កីឡាករ កីឡាការិនីសាកលវិទ្យាល័យ** ( University Games )

ក.១ -ការប្រកួតកីឡាសាកលវិទ្យាល័យពិភពលោក

| | | | | |
|---|---|---|---|---|
| -មេដាយមាស | ផ្តល់ជូន | ០១នាក់ | ចំនួន | ២០.០០០.០០០ រៀល |
| -មេដាយប្រាក់ | ផ្តល់ជូន | ០១នាក់ | ចំនួន | ១៦.០០០.០០០ រៀល |
| -មេដាយសំរិទ្ធិ | ផ្តល់ជូន | ០១នាក់ | ចំនួន | ១៣.០០០.០០០ រៀល |

ក.២ -ការប្រកួតកីឡាសាកលវិទ្យាល័យអាស៊ី

| | | | | |
|---|---|---|---|---|
| -មេដាយមាស | ផ្តល់ជូន | ០១នាក់ | ចំនួន | ១៦.០០០.០០០ រៀល |
| -មេដាយប្រាក់ | ផ្តល់ជូន | ០១នាក់ | ចំនួន | ១៣.០០០.០០០ រៀល |
| -មេដាយសំរិទ្ធិ | ផ្តល់ជូន | ០១នាក់ | ចំនួន | ១១.០០០.០០០ រៀល |

ក.៣ -ការប្រកួតកីឡាសាកលវិទ្យាល័យអាស៊ី-អាគ្នេយ៍

| | | | | |
|---|---|---|---|---|
| -មេដាយមាស | ផ្តល់ជូន | ០១នាក់ | ចំនួន | ៩.០០០.០០០ រៀល |
| -មេដាយប្រាក់ | ផ្តល់ជូន | ០១នាក់ | ចំនួន | ៨.០០០.០០០ រៀល |
| -មេដាយសំរិទ្ធិ | ផ្តល់ជូន | ០១នាក់ | ចំនួន | ៧.០០០.០០០ រៀល |

**ខ-ប្រាក់រង្វាន់លើកទឹកចិត្ត កីឡាករ កីឡាការិនីជើងឯកតាមប្រភេទកីឡា** (Championship)

ខ.១ -ការប្រកួតកីឡាជើងឯកពិភពលោក

| | | | | |
|---|---|---|---|---|
| -មេដាយមាស | ផ្តល់ជូន | ០១នាក់ | ចំនួន | ២០.០០០.០០០ រៀល |
| -មេដាយប្រាក់ | ផ្តល់ជូន | ០១នាក់ | ចំនួន | ១៦.០០០.០០០ រៀល |
| -មេដាយសំរិទ្ធិ | ផ្តល់ជូន | ០១នាក់ | ចំនួន | ១៣.០០០.០០០ រៀល |

ខ.២ -ការប្រកួតកីឡាជើងឯកអាស៊ី

| | | | | |
|---|---|---|---|---|
| -មេដាយមាស | ផ្តល់ជូន | ០១នាក់ | ចំនួន | ១៦.០០០.០០០ រៀល |
| -មេដាយប្រាក់ | ផ្តល់ជូន | ០១នាក់ | ចំនួន | ១៣.០០០.០០០ រៀល |
| -មេដាយសំរិទ្ធិ | ផ្តល់ជូន | ០១នាក់ | ចំនួន | ១១.០០០.០០០ រៀល |

ខ.៣ -ការប្រកួតកីឡាជើងឯកអាស៊ី-អាគ្នេយ៍

| | | | | |
|---|---|---|---|---|
| -មេដាយមាស | ផ្តល់ជូន | ០១នាក់ | ចំនួន | ៩.០០០.០០០ រៀល |
| -មេដាយប្រាក់ | ផ្តល់ជូន | ០១នាក់ | ចំនួន | ៨.០០០.០០០ រៀល |
| -មេដាយសំរិទ្ធិ | ផ្តល់ជូន | ០១នាក់ | ចំនួន | ៧.០០០.០០០ រៀល |

**គ-ដោយឡែកប្រាក់រង្វាន់លើកទឹកចិត្តកីឡាករ កីឡាការិនីដែលទទួលបានជ័យលាភី** JEUX FRANCOPHONIE, ARAFURA GAMES និង MEKONG GOODWILL GAMES ត្រូវបានកំណត់ដូចខាងក្រោម ៖

គ.១ - JEUX FRANCOPHONIE

| | | | | |
|---|---|---|---|---|
| -មេដាយមាស | ផ្តល់ជូន | ០១នាក់ | ចំនួន | ១៦.០០០.០០០ រៀល |
| -មេដាយប្រាក់ | ផ្តល់ជូន | ០១នាក់ | ចំនួន | ១៣.០០០.០០០ រៀល |
| -មេដាយសំរិទ្ធិ | ផ្តល់ជូន | ០១នាក់ | ចំនួន | ១១.០០០.០០០ រៀល |

គ.២ - ARAFURA GAMES

| | | | | |
|---|---|---|---|---|
| -មេដាយមាស | ផ្តល់ជូន | ០១នាក់ | ចំនួន | ១២.០០០.០០០ រៀល |
| -មេដាយប្រាក់ | ផ្តល់ជូន | ០១នាក់ | ចំនួន | ១០.០០០.០០០ រៀល |
| -មេដាយសំរិទ្ធិ | ផ្តល់ជូន | ០១នាក់ | ចំនួន | ៨.០០០.០០០ រៀល |

គ.៣ - MEKONG GOODWILL GAMES

| | | | | |
|---|---|---|---|---|
| -មេដាយមាស | ផ្តល់ជូន | ០១នាក់ | ចំនួន | ៣.០០០.០០០ រៀល |
| -មេដាយប្រាក់ | ផ្តល់ជូន | ០១នាក់ | ចំនួន | ២.០០០.០០០ រៀល |
| -មេដាយសំរឹទ្ធិ | ផ្តល់ជូន | ០១នាក់ | ចំនួន | ១.០០០.០០០ រៀល |

**ឃ**-គ្រូបង្វឹកត្រូវបានផ្តល់ប្រាក់ឧបត្ថម្ភស្មើនឹងប្រាក់រង្វាន់ជ័យលាភី ដែលទទួលបានចំណាត់ថ្នាក់មេដាយខ្ពស់ជាងគេក្នុងវិញ្ញាសាប្រកួតដែលខ្លួនទទួលបន្ទុកបង្វឹក ។

-គ្រូជំនួយត្រូវទទួលបានប្រាក់ឧបត្ថម្ភស្មើនឹងចំនួន ៧០% នៃប្រាក់ឧបត្ថម្ភសម្រាប់គ្រូបង្វឹក ។

**ខ-ប្រាក់រង្វាន់លើកទឹកចិត្តដល់ជ័យលាភីជាក្រុម**

ការផ្តល់ប្រាក់រង្វាន់ជាក្រុម ត្រូវយករង្វាន់ឯកត្តជន គុណនឹងចំនួនកីឡាករ តាមនិយាមបច្ចេកទេសនៃការប្រកួតអន្តរជាតិ ។

**ប្រការ ៧.-**

ការផ្តល់ប្រាក់ឧបត្ថម្ភខាងលើសម្រាប់តែការប្រមូលផ្តុំហ្វឹកហាត់ និងការចេញទៅប្រកួតជាលក្ខណៈអន្តរជាតិក្នុង និងក្រៅប្រទេសទាំងឡាយណា ដែលទទួលបានការអនុញ្ញាតរៀបចំចាត់តាំងស្របតាមនិយាមបច្ចេកទេសតាមរយៈអង្គភាពជំនាញ នៃក្រសួងអប់រំ យុវជន និងកីឡា តាមឋានានុក្រម ។

**ប្រការ ៨.-**

ការចេញទៅប្រកួតជាលក្ខណៈអន្តរជាតិនៅក្នុងប្រទេស និងក្រៅប្រទេសគ្រប់កម្រិត ដែលមានការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា ដែលជាអាណាព្យាបាល តាមរយៈអង្គភាពជំនាញ ហើយទទួលបានជ័យលាភីនឹងត្រូវទទួលប្រាក់រង្វាន់លើកទឹកចិត្តពីរដ្ឋ ។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**ប្រការ ៩.-**

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ១០.-**

គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា មានភារកិច្ច អនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាពខ្ពស់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ ២០១៥

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** **រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន** **បណ្ឌិត ហង់ ជួន ណារ៉ុន**

**កន្លែងទទួល ៖**

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ទីស្តីការគណៈរដ្ឋមន្ត្រី

-អាជ្ញាធរសេវាកម្មជាតិ

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

*«ដើម្បីជូនជ្រាប»*

-ដូចប្រការ ១០ *«ដើម្បីអនុវត្ត»*

-កាលប្បវត្តិ-ឯកសារ